ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ១០២០ ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌ និងទម្រង់បែបបទនៃការដាក់ពាក្យស្នើសុំការអនុញ្ញាត ប្រកបអាជីវកម្មផ្តល់សេវាសន្តិសុខឯកជន និងការជ្រើសរើសភ្នាក់ងារសន្តិសុខឯកជន

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១០៩អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៣៩ អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា៩ មាត្រា១០ មាត្រា៤២ និងមាត្រា៤៥ នៃអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២៤០អនក្រ.បក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការបង្កើតនាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន និងនាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ២៨៩អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការគ្រប់គ្រងសន្តិសុខឯកជន
- យោងតាមសំណើរបស់អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ

## សម្រេច

**ប្រការ១.-**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មផ្តល់សេវាសន្តិសុខឯកជន ត្រូវបំពេញលក្ខខណ្ឌ និងទម្រង់បែបបទនៅនាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ដូចខាងក្រោម៖

១- ពាក្យសុំប្រកបអាជីវកម្មផ្តល់សេវាសន្តិសុខឯកជន ចំនួន០១ច្បាប់
២- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ចំនួន០២ច្បាប់
៣- ប្រវត្តិរូបសង្ខេបរបស់ប្រធានក្រុមហ៊ុន និងគ្រប់ម្ចាស់ភាគហ៊ុន ចំនួន០២ច្បាប់
៤- អត្តសញ្ញាណប័ណ្ណថតចម្លងពណ៌ធម្មជាតិ ចំនួន០២ច្បាប់

| | |
|---|---|
| ៥- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារថតចម្លងពណ៌ធម្មជាតិ | ចំនួន០២ច្បាប់ |
| ៦- សេចក្តីចម្លងសំបុត្រកំណើត | ចំនួន០២ច្បាប់ |
| ៧- លិខិតបញ្ជាក់ទីលំនៅ | ចំនួន០២ច្បាប់ |
| ៨- លិខិតថ្កោលទោស | ចំនួន០២ច្បាប់ |
| ៩- នាមករណ៍ក្រុមហ៊ុន និងស្លាកសញ្ញាសម្គាល់ភ្នាក់ងារសន្តិសុខឯកជន | ចំនួន០២ច្បាប់ |
| ១០- រូបថតតំរូវឯកសណ្ឋានភ្នាក់ងារសន្តិសុខឯកជនមានស្លាកសញ្ញាក្រុមហ៊ុន | ចំនួន០២ច្បាប់ |
| ១១- រូបថតគំរូឧបករណ៍ សម្ភារបច្ចេកទេស មធ្យោបាយ សត្វ សម្រាប់បំពាក់ឲ្យភ្នាក់ងារសន្តិសុខឯកជន | ចំនួន០២ច្បាប់ |
| ១២- រូបថតប្រធានក្រុមហ៊ុន និងគ្រប់ម្ចាស់ភាគហ៊ុនទំហំ៤ស.ម គុណ៦ស.ម (ម្នាក់) | ចំនួន០៨សន្លឹក |
| ១៣- លិខិតបញ្ជាក់បានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ថតចម្លង | ចំនួន០២ច្បាប់ |
| ១៤- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និងកិច្ចសន្យាជួលទីតាំង ថតចម្លង | ចំនួន០២ច្បាប់ |
| ១៥- ករណីប្រធានក្រុមហ៊ុន ឬម្ចាស់ភាគហ៊ុនជាជនបរទេសត្រូវថតចម្លងពណ៌ធម្មជាតិលិខិតឆ្លងដែន និងទិដ្ឋាការនៅមានសុពលភាព | ចំនួន០២ច្បាប់ |
| ១៦- វិក្កយបត្របង់ប្រាក់ | ចំនួន០២ច្បាប់ ។ |

**ប្រការ២..**

បន្ទាប់ពីបានទទួលសំណុំឯកសារតាមលក្ខខណ្ឌ និងទម្រង់បែបបទនៃពាក្យសុំប្រកបអាជីវកម្មផ្តល់សេវាសន្តិសុខឯកជន ប្រធាននាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន ត្រូវពិនិត្យ និងលើកយោបល់ជូនអគ្គស្នងការនគរបាលជាតិ ក្នុងរយៈពេល២០ថ្ងៃ (ម្ភៃ) ថ្ងៃ នៃថ្ងៃធ្វើការងារ ។

អគ្គស្នងការនគរបាលជាតិត្រូវពិនិត្យ និងលើកយោបល់ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីពិនិត្យសម្រេច ក្នុងរយៈពេល១០ថ្ងៃ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការងារ ។

**ប្រការ៣ ..**

ក្រសួងមហាផ្ទៃ អាចអនុញ្ញាតឲ្យក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជនបង្កើតភ្នាក់ងារសន្តិសុខឯកជនក្នុងរយៈពេល៣០ថ្ងៃ (សាបសិប) ថ្ងៃ បន្ទាប់ពីបានបំពេញលក្ខខណ្ឌ និងទម្រង់បែបបទត្រឹមត្រូវរួចហើយ ។

ក្នុងករណីក្រសួងមហាផ្ទៃ មិនអនុញ្ញាតឲ្យក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជនបង្កើតភ្នាក់ងារសន្តិសុខឯកជន អគ្គស្នងការដ្ឋាននគរបាលជាតិ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដោយលើកពីមូលហេតុ ឬហេតុផលពីការមិនអនុញ្ញាតជូនទៅដល់សាមីអ្នកស្នើសុំក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការងារបន្ទាប់ពីបានទទួលសំណុំឯកសារ ។

**ប្រការ៤ ..**

ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន ត្រូវចុះកិច្ចសន្យាសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិ យ៉ាងយូរ០៦ខែ (ប្រាំមួយ) ក្រោយពីទទួលបានការអនុញ្ញាតចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ដើម្បីដំណើរការត្រឹមត្រូវតាមច្បាប់ ។

**ប្រការ៥ ..**

ក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជនត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតប្រើរថយន្តដឹកជញ្ជូនប្រាក់ ទ្រព្យសម្បត្តិ និងវត្ថុមានតម្លៃមកអគ្គស្នងការដ្ឋាននគរបាលជាតិ តាមរយៈនាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន និងត្រូវស្នើកងកម្លាំងនគរបាលជាតិមានសមត្ថកិច្ច ដើម្បីសហការការពារ និងអមការពាររថយន្តដឹកជញ្ជូនប្រាក់ ទ្រព្យសម្បត្តិ និងវត្ថុមានតម្លៃ ។ ៚

**ប្រការ៦..**

ម្ចាស់សហគ្រាសគ្រឹះស្ថាននានាដែលមានបំណងជ្រើសរើសភ្នាក់ងារសន្តិសុខឯកជន ត្រូវបំពេញលក្ខខណ្ឌ និងទម្រង់បែបបទនៅការិយាល័យគ្រប់គ្រងសន្តិសុខឯកជន នៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ដូចខាងក្រោម ៖

| | |
|---|---|
| ១- ពាក្យសុំជ្រើសរើសភ្នាក់ងារសន្តិសុខឯកជន | ចំនួន០១ច្បាប់ |
| ២- បទបញ្ជាផ្ទៃក្នុង និងរចនាសម្ព័ន្ធគ្រប់គ្រងភ្នាក់ងារសន្តិសុខឯកជន | ចំនួន០២ច្បាប់ |
| ៣- ប្រវត្តិរូបសង្ខេបរបស់ម្ចាស់សហគ្រាសគ្រឹះស្ថាននានា | ចំនួន០២ច្បាប់ |
| ៤- អត្តសញ្ញាណប័ណ្ណថតចម្លងពណ៌ធម្មជាតិ | ចំនួន០២ច្បាប់ |
| ៥- សៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារថតចម្លងពណ៌ធម្មជាតិ | ចំនួន០២ច្បាប់ |
| ៦- សេចក្តីចម្លងសំបុត្រកំណើត | ចំនួន០២ច្បាប់ |
| ៧- លិខិតបញ្ជាក់ទីលំនៅ | ចំនួន០២ច្បាប់ |
| ៨- លិខិតថ្កោលទោស | ចំនួន០២ច្បាប់ |
| ៩- នាមករណ៍ក្រុមហ៊ុន និងស្លាកសញ្ញាសម្គាល់ភ្នាក់ងារសន្តិសុខឯកជន | ចំនួន០២ច្បាប់ |
| ១០- រូបថតគំរូឯកសណ្ឋានភ្នាក់ងារសន្តិសុខឯកជនមានស្លាកសញ្ញាក្រុមហ៊ុន | ចំនួន០២ច្បាប់ |
| ១១- រូបថតគំរូឧបករណ៍ សម្ភារបច្ចេកទេស មធ្យោបាយ សត្វ សម្រាប់បំពាក់ឲ្យភ្នាក់ងារសន្តិសុខឯកជន | ចំនួន០២ច្បាប់ |
| ១២- រូបថតប្រធានម្ចាស់សហគ្រាសគ្រឹះស្ថាននានាទំហំ៤ស.ម គុណ៦ស.ម (ម្នាក់) | ចំនួន០៨សន្លឹក |
| ១៣- លិខិតបញ្ជាក់បានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម ថតចម្លង | ចំនួន០២ច្បាប់ |
| ១៤- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និងកិច្ចសន្យាជួលទីតាំង ថតចម្លង | ចំនួន០២ច្បាប់ |
| ១៥- ករណីម្ចាស់សហគ្រាសគ្រឹះស្ថាននានាជាជនបរទេសត្រូវថតចម្លងពណ៌ធម្មជាតិលិខិតឆ្លងដែន និងទិដ្ឋាការនៅមានសុពលភាព | ចំនួន០២ច្បាប់ |
| ១៦- វិក្កយបត្របង់ប្រាក់ | ចំនួន០២ច្បាប់ ។ |

**ប្រការ៧..**

បន្ទាប់ពីបានទទួលសំណុំឯកសារតាមលក្ខខណ្ឌ និងទម្រង់បែបបទនៃពាក្យសុំជ្រើសរើសភ្នាក់ងារសន្តិសុខឯកជន ប្រធានការិយាល័យគ្រប់គ្រងសន្តិសុខឯកជនរាជធានី ខេត្ត ត្រូវពិនិត្យ និងលើកយោបល់ជូនស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ក្នុងរយៈពេល២០ថ្ងៃ (ម្ភៃ) ថ្ងៃ នៃថ្ងៃធ្វើការងារ ។

ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវពិនិត្យ និងលើកយោបល់ជូនរដ្ឋបាលរាជធានី ខេត្ត ដើម្បីពិនិត្យសម្រេចក្នុងរយៈពេល១០ (ដប់) ថ្ងៃ នៃថ្ងៃធ្វើការងារ ។

**ប្រការ៨..**

រដ្ឋបាលរាជធានី ខេត្ត អាចអនុញ្ញាតឲ្យសហគ្រាសគ្រឹះស្ថាននានាបង្កើតភ្នាក់ងារសន្តិសុខឯកជន ក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃបន្ទាប់ពីបានបំពេញលក្ខខណ្ឌ និងទម្រង់បែបបទត្រឹមត្រូវរួចហើយ ។

ក្នុងករណីរដ្ឋបាលរាជធានី ខេត្ត មិនអនុញ្ញាតឲ្យសហគ្រាសគ្រឹះស្ថាននានាបង្កើតភ្នាក់ងារសន្តិសុខឯកជន ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដោយលើកពីមូលហេតុ ឬហេតុផលពីការមិនអនុញ្ញាតជូនទៅដល់សាមីអ្នកស្នើសុំក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការងារបន្ទាប់ពីបានទទួលសំណុំឯកសារ ។ ៚

**ប្រការ៩..**

សហគ្រាសគ្រឹះស្ថាននានាត្រូវចុះកិច្ចសន្យាសហការជាមួយស្នងការដ្ឋាននគរបាលរាជធានី ខេត្ត យ៉ាងយូរ ០៣ខែ (បី) ក្រោយពីទទួលបានការអនុញ្ញាតពីរដ្ឋបាលរាជធានី ខេត្ត ដើម្បីដំណើរការត្រឹមត្រូវតាមច្បាប់ ។

**ប្រការ១០..**

សហគ្រាសគ្រឹះស្ថាននានាត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតប្រើរថយន្តដឹកជញ្ជូនប្រាក់ ទ្រព្យសម្បត្តិ និងវត្ថុមានតម្លៃមកស្នងការដ្ឋាននគរបាលរាជធានី ខេត្ត តាមរយៈការិយាល័យគ្រប់គ្រងសន្តិសុខឯកជនរាជធានី ខេត្ត និងត្រូវស្នើកងកម្លាំងនគរបាលជាតិមានសមត្ថកិច្ច ដើម្បីសហការការពារ និងអមការពាររថយន្តដឹកជញ្ជូនប្រាក់ ទ្រព្យសម្បត្តិ និងវត្ថុមានតម្លៃ ។

**ប្រការ១១..**

ប្រកាសលេខ២៦១ប្រ.ក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីលក្ខខណ្ឌ និងទម្រង់បែបបទនៃការដាក់ពាក្យស្នើសុំការអនុញ្ញាតប្រកបអាជីវកម្មផ្តល់សេវាសន្តិសុខឯកជន និងការជ្រើសរើសភ្នាក់ងារសន្តិសុខឯកជន និងការកំណត់ទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ និងជំនួសដោយប្រកាសនេះ ។

**ប្រការ១២..**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងស្នងការនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ ៚

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចឧបនាយករដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការពារជាតិ
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១២
(ដើម្បីអនុវត្ត)
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ